មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

លេខ: 00445/13 ម.ស.ម.ក/

សូមគោរពជូន

ឯកឧត្តម ស ខេង

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

កម្មវត្ថុ៖ សូមឯកឧត្តមមេត្តាជួយអន្តរាគមន៍ លើករណីគំរាមកំហែងពីសំណាក់ប្រធានសហគមន៍ភូមិអណ្តូង ៤ លោក ទេព ណាន់ មកលើអ្នកស្រី យ៉ង់ សោភ័ណ្ឌ និងករណីដែលមន្ត្រីសង្កាត់គោករកាមិនព្រមទទួលពាក្យបណ្តឹងលើករណីគំរាមកំហែងនេះ ដែលប្រព្រឹត្តក្នុងកំឡុង ថ្ងៃទី ២៥ ដល់ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣។

យោង៖ លិខិតស្នើសុំអន្តរាគមន៍ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៣ របស់អ្នស្រី យ៉ង់ សោភ័ណ្ឌ ផ្ញើមកមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំមានកិត្តិយស សូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា កាលពីថ្ងៃច័ន្ទ ទី២៥ ខែមីនា ឆ្នាំ២០១៣ ក្រុមការងារនៃគម្រោងកំណែទម្រង់ដីធ្លី របស់ ម.ស.ម.ក បានចុះទៅភូមិអណ្តូង សង្កាត់គោករកា ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ចម្ងាយប្រមាណជា ៨គីឡូម៉ែត្រ ពីព្រលានយន្តហោះអន្តរជាតិភ្នំពេញ ជាតំបន់លំនៅឋានថ្មីសម្រាប់អ្នកភូមិដែលត្រូវបានបណ្តេញចេញពីភូមិ សំបុកចាប កាលពីឆ្នាំ២០០៦។ ក្រុមការងាររបស់ ម.ស.ម.ក មានគម្រោងចុះទៅសម្ភាសន៍ និងធ្វើការស្រាវជ្រាវពាក់ព័ន្ធស្ថានភាពសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋ ដែលត្រូវបានបណ្តេញចេញទាំងនោះ។ ពេលក្រុមការងារធ្វើដំណើរជិតដល់ភូមិអណ្តូង លោក វណ្ណ សុផាត ដែលជាអ្នកដឹកនាំក្រុម បានទទួលទូរស័ព្ទពីលោក យាន នៅ ដែលជាតំណាងអាជ្ញាធរសង្កាត់គោករកា បានបដិសេធមិនព្រមឲ្យក្រុមការងាររបស់ ម.ស.ម.ក បានចូលជួបសម្ភាសន៍ប្រជាពលរដ្ឋនៅតំបន់នោះឡើយ ដោយអះអាងថា ម.ស.ម.ក ត្រូវសុំការអនុញ្ញាតពីអាជ្ញាធរជាមុនសិនដើម្បីចូលទៅកាន់សហគមន៍នេះ។

ដើម្បីដោះស្រាយបញ្ហានេះ ក្រុមការងាររបស់ ម.ស.ម.ក បានជួបប្រជុំដោយផ្ទាល់មាត់ជាមួយនឹងអាជ្ញាធរ បន្ទាប់ពីពិភាក្សាគ្នារួចក្រុមការងារនេះ ត្រូវបានអនុញ្ញាតឲ្យចូលទៅសហគមន៍ និងជួបសម្ភាសន៍ជាមួយប្រជាពលរដ្ឋ។

អ្នកភូមិពីរនាក់ ក្នុងភូមិអណ្តូង៤ គឺ អ្នកស្រី យ៉ង់ សោភ័ណ្ឌ និង លោក ហ៊ិន សុភា បានជួយដល់ក្រុមការងាររបស់ ម.ស.ម.ក យ៉ាងច្រើន ក្នុងអំឡុងពេលទស្សនកិច្ចនេះ ថែមទាំងជួយណែនាំក្រុមការងារ និងសម្របសម្រួលដល់ការសម្ភាសន៍ថែមទៀតផង។

មួយថ្ងៃក្រោយពីទស្សនកិច្ច លោក ទេព ណាន់ បានប្រើពាក្យសម្តី ប្រមាថដល់អាយុជីវិតរបស់អ្នកស្រី យ៉ង់ សោភ័ណ្ឌ នៅចំពោះមុខមហាជនថា "វាយយាយកណ្តុំបំបែកក្បាល" ។ លោកស្រី យ៉ង់ សោភ័ណ្ឌ បានទៅជួបជាមួយលោក ទេព ណាន់ ក្នុងយប់ថ្ងៃដដែល វេលាម៉ោង ២១:៣០នាទី ដើម្បីសួរនាំរឿងរ៉ាវដែលលោក ទេព ណាន់ និយាយប្រមាថអាយុជីវិតអ្នកស្រីស្រាប់តែពេលនោះ លោក ទេព ណាន់ នៅតែប្រើពាក្យអសុរោះជាច្រើន និងយកដំបងឬស្សីបំរុងនឹងវាយមកលើអ្នកស្រី យ៉ង សោភ័ណ្ឌ ដោយមានសាក្សីជាអ្នកភូមិបានដឹងឮជាច្រើននាក់។

អាសយដ្ឋាន ផ្ទះលេខ ៧៩៨ ផ្លូវលេខ ៩៩, សង្កាត់បឹងត្របែក ខណ្ឌចំការមន, ប្រអប់សំបុត្រលេខ ១៤០៦, រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: ០២៣ ៧២៦ ៩០១ ទូរសារ: ០២៣ ៧២៦ ៩០២ អ៊ីមែល: info@cchrcambodia.org វេបសាយ: www.cchrcambodia.org

នៅព្រឹកថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣ អ្នកស្រី យ៉ង់ សោភ័ណ្ឌ បានទៅដាក់ពាក្យបណ្តឹងនៅសង្កាត់គោករកា ស្តីពីការគំរាមដែលលោក ទេព ណាន់ បានប្រព្រឹត្តមកលើអ្នកស្រី ប៉ុន្តែ លោក យាន នៅ ជាមន្ត្រីសង្កាត់ បានច្រានចោលពាក្យ បណ្តឹងដោយបោះទៅលើកៅអី ហើយថែមទាំងប្រើពាក្យអសុរោះខ្លាំងៗថា អ្នកស្រីជាមេខ្លោងបះបោរនាំប្រជាពលរដ្ឋឲ្យសម្ភាសន៍ជាមួយក្រុមការងារ ម.ស.ម.ក និងថែមទាំងនិយាយគំរាមទៀតថា "មើងឯងប្រយ័ត្នខ្លួនចាប់ពីថ្ងៃនេះតទៅ"។

ម.ស.ម.ក សូមបញ្ជាក់ថា នេះមិនមែនដូចការអះអាងរបស់លោក យាន នៅ នោះទេ។ ទស្សនកិច្ចរបស់ក្រុមការងារ នៃ ម.ស.ម.ក មិនមែនដោយសារតែអ្នកស្រី យ៉ង សោភ័ណ្ឌ នោះឡើយ តែគឺជាបេសកកម្មចាំបាច់របស់ ម.ស.ម.ក ក្នុងការស្រាវជ្រាវដើម្បីស្វែងយល់ពីស្ថានភាពសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋសហគមន៍ បន្ទាប់ពីការបណ្តេញចេញប៉ុណ្ណោះ។

សកម្មភាពគំរាមកំហែងរបស់ លោក ទេព ណាន់ និងការបដិសេធមិនព្រមទទួលពាក្យបណ្តឹងរបស់ លោក យាន នៅ បានបំពានកាតព្វកិច្ចរបស់ខ្លួនជាអាជ្ញាធរដែនដី និងរំលោភលើគោលការណ៍សិទ្ធិមនុស្ស ដែលបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣១ និងច្បាប់អន្តរជាតិ។ សិទ្ធិទាំងនេះរួមមាន សិទ្ធិសេរីភាពបញ្ចេញមតិ (មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ) សិទ្ធិសេរីភាពក្នុងការប្រជុំ (មាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ) សិទ្ធិសេរីភាពក្នុងការដើរហើរ (មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ) និងសិទ្ធិចូលរួមក្នុងសកម្មភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (មាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញ)។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជួយធ្វើអន្តរាគមន៍ និងចាត់វិធានការលើករណីខាងលើដើម្បីការពារដល់សិទ្ធិសេរីភាពបញ្ចេញមតិរបស់ប្រជាពលរដ្ឋ និងដើម្បីបង្ហាញថាប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិស្មើៗគ្នា និងដើម្បីធានាដល់សុវត្ថិភាពរបស់អ្នកស្រី យ៉ង់ សោភ័ណ្ឌ និងប្រជាពលរដ្ឋសហគមន៍នោះផង។

សូមឯកឧត្តមមេត្តាទទួលនូវក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០១៣

ប្រធាន

អ៊ូ ទីរៈ

ភ្ជាប់មកជាមួយនូវ៖
-លិខិតស្នើសុំអន្តរាគមន៍របស់អ្នកស្រី យ៉ង់ សោភ័ណ្ឌ
មកកាន់មជ្ឈមណ្ឌលសិទ្ធមនុស្សកម្ពុជា

ចម្លងជូន៖
-សាលារាជធានីភ្នំពេញ
-សាលាខណ្ឌពោធិ៍សែនជ័យ
-សាលាសង្កាត់គោករកា

ព័ត៌មានបន្ថែមសូមទាក់ទង៖
ទូរស័ព្ទលេខ៖ ០១២ ៤០៤ ០៥១
អ៊ីម៉ែល៖ ouvirak@cchrcambodia.org

ព្រះមហាក្សត្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតស្នើសុំសន្ធឹកគម្រោង

ឯកឧត្តម យ៉ាម ណារិទ្ធ ទេសត្រី អាយុ 56 ឆ្នាំ មានទីលំនៅ
ក្នុងសហគមន៍ភូមិសណ្តាប់ 4 សង្កាត់ត្រពាំងកក ខណ្ឌចោមចៅ រាជធានីភ្នំពេញ
រួមជាមួយបងប្អូន នៃលេខាធិការដ្ឋានក្រុមភ្នំពេញ។

សូមគោរពជូន

ឯកឧត្តម : លោកប្រធាន មជ្ឈមណ្ឌល សិទ្ធិមនុស្សកម្ពុជា
សំណើរសុំជួយសន្ធឹកគម្រោងពី មជ្ឈមណ្ឌល សិទ្ធិមនុស្សកម្ពុជា
ជួយរកយុត្តិធម៌ឲ្យបងខ្ញុំ តាមដែលបានរៀបរាប់។

ជាបងខ្ញុំមានកិត្តិយស សូមជំរាបជូនលោកប្រធាន មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
ពីបញ្ហាដែលបណ្តាលមូលហេតុដូចតទៅ៖
គិតចាប់ពីថ្ងៃទី 25 ខែ មិថុនា ឆ្នាំ 2013 ជាបងខ្ញុំនិងបងប្អូនប្រជាពលរដ្ឋ
នៅតំបន់សហគមន៍ភូមិសណ្តាប់ 4 ជាច្រើនរាក់ទាក់ មានសំណើរថា សង្គមការ
មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា មកជួបពួកយើងខ្ញុំ ដើម្បីឲ្យពួកយើងខ្ញុំបាន
បង្ហាញមតិ តាមរយៈកម្រងសំលេងរបស់ពួកយើងខ្ញុំតាមរយៈសង្គមការ PCL
(People for care and learning) សហការជាមួយអង្គការជំនួយ
និងរូបភាពរបស់ពួកយើងខ្ញុំ។ ដូចនេះពួកយើងខ្ញុំសប្បាយរីករាយ ចង់ជួប
ក្រុមការងារ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដើម្បីបង្ហាញមតិ ក្រាប់ដល់ពួក
គាត់ (ក្រុមការងារ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា)។ ប៉ុន្តែមុនក្រុមការងារ
មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ចំណងដឹកនាំដោយលោក វណ្ណ សុជាត មកដល់ទីតាំង
តំបន់សហគមន៍ភូមិសណ្តាប់ 4 ស្រាប់តែលោកទទួលបាន ប្រធានសហគមន៍
ភូមិសណ្តាប់ 4 ចំណុះក្នុងប្រកាសចំនួនតាមរយៈសារអេឡិចត្រូនិច
ឯកឧត្តម ចែប ប៊ុនធឿ ថ្ងៃទី 19 មិថុនា ឆ្នាំ 2013 ហៅក្បាលសហគមន៍

ភូមិសណ្តប់ ៤ លោក ទេព ណាន់ បានបញ្ជាក្បួនខ្មួនគំហកថាមិនអាច
ប្រើពលរដ្ឋទៅបញ្ចុះញ្ចូលបានទេ ដើម្បីសំភាសន៍ជាមួយក្រុមការងារក្រុមមជ្ឈមណ្ឌល
សិទ្ធិមនុស្សកម្ពុជាទេ ហើយលោក ទេព ណាន់ បានប្រើពាក្យគំហកថា
ប្រើអ្នកណា ហើយទៅបញ្ចុះញ្ចូលបានទេ ឬសំភាសន៍ជាមួយក្រុមមជ្ឈមណ្ឌលសិទ្ធិ
មនុស្សកម្ពុជា ប្រយ័ត្នខ្លួនបានដែរ ទាត់ចាប់ផ្តើម ៤ ព្រឹកឡើងបន្តិចមក ក្រុមការងារ
មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ក៏ចាកដើរទីតាំង សហគមន៍ភូមិសណ្តប់ ៤ ក៏ជួបជា
មួយអាជ្ញាធរខ្លះនៅ នៅលើមានលោកមេភូមិសណ្តប់ សុខ ឆាំ លោក ទេព ណាន់
ប្រធាន សហគមន៍ភូមិសណ្តប់ ៤ លោក ងាល ឌីម ប្រធានសន្តិសុខ សហគមន៍
ក្នុងការងារ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានប្រាប់ពីរឿងរបៀបមកជួប
ប្រជាពលរដ្ឋក្នុងសហគមន៍ ព្រឹកឡើងមក អាជ្ញាធរក៏បានមកប្រាប្តឹងរឿងក្រុម
ការងារ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ចូលទៅក្នុងសហគមន៍ដើម្បីសំភាសន៍ជាមួយ
ប្រជាពលរដ្ឋ ។ ពួកយើងខ្ញុំជាប្រជាពលរដ្ឋ ក៏បានសំភាសន៍ និងបញ្ជាក្បួនមតិ
ពីទុក្ខកង្វល់របស់យើងខ្ញុំ (ប្រជាពលរដ្ឋ) ។ រឿងពីបញ្ហាបណ្តាញចរាចរ
និងវិវរ៉ែ ដែលតាមពិតភាគច្រើនយើងធ្លាប់ឮៗ ដែលបណ្តាលមកពីក្រុមការងារ
មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ទោះជាមានការគំរាមកំហែងពីលោក ទេព ណាន់
យ៉ាងណា ក៏ដោយពួកខ្ញុំនៅតែសំភាសន៍ជាមួយក្រុមការងារមជ្ឈមណ្ឌលសិទ្ធិមនុស្ស
កម្ពុជា រហូតបានចប់សព្វគ្រប់ ។

ព្រឹកថ្ងៃ អង្គារទី 26 ខែមីនា ឆ្នាំ 2013 មានឡានមួយឡូតបានកើតឡើង
ប្រមាណវេលាម៉ោង 9 ព្រឹក លោក ទេព ណាន់ បានប្រើពាក្យសំដីប្រមាថ
អាយុដីវិត ជាមខ្ញុំ (ឃាំ សោភ័ណ្ឌ) ដែលចំពោះមុខមហាជនថា << ទំនិញយួន
ភាំណ្ឌ បំពែកក្បាល >> ។ រហែយបន្តិចទៀត (ទី26 ខែមីនា ឆ្នាំ 2013) ម៉ោង
21:30 ទាទី ជាប់ខ្ញុំបានទៅសួរសុខទុក្ខក្មួយប្រុសរបស់ខ្ញុំ (ទេព ណាន់) បាន
ប្រើពាក្យសំដីប្រមាថ អាយុដីវិតជាប់ខ្ញុំ ពេលនោះគ្រាន់តែលោក ទេព ណាន់
ដើរតែប្រើពាក្យអសុរស ជាច្រើន និងបែរកន្ទបបឹងឬស្សីបំរុងនឹងវាយមកលើ
ជាប់ខ្ញុំទៀតផង ជាប់ខ្ញុំមានលោកស្រីបានជំរិលឈ្លួតផង ។

ក្មួយប្រុសទាំងពីរនាក់នេះសរបញ្ជាក់ឲ្យដឹងច្បាស់ថា ប្រធានសហគមន៍លោក
ទេព ណាន់ ជាប្រធានសហគមន៍មិនគោរពសិទ្ធិប្រជាពលរដ្ឋ ហើយតំណាងប្រ

តវាមតំហែង បំបិទសិទ្ធិសេរីភាពប្រជាពលរដ្ឋ ។ ដូចេ្នះខ្ញុំសូមស្នើសុំ
ក្រុម ព័ត៌មាន ដើម្បីឯកភ្ជួតមាតប្រសាសន៍ជាឲ្យប្រធានសហគមន៍ស្រលាញ់
យកចិត្តទុកដាក់ ការពារ បំរើ ផ្តល់ត្រជាំ ងាយបំផ្តើដល់ប្រជាពលរដ្ឋតំណាង
ល្អតល្អប៉ ។

លោងចូលដល់ថ្ងៃទី 27 ខែ មិថុនា ឆ្នាំ 2013 លោងខ្ញុំ (យ៉ាប់ សោតណ្ឌ) បាន
ធ្វើពាក្យបណ្តឹងមួយច្បាប់ដាក់ជូនសាលាស្រុកគោកធ្លក ដោយចោទប្រកាន់ពីបទ
ពីរធាងំភ្ជាំពាក្យ ដើម្បីសម្រាយលោកថាសង្ការីជួយដោះស្រាយទូរបញ្ហាដូចបាន
ស្នើបង់ហាងលើ ពាក្យបណ្តឹងត្រូវបានមន្ត្រីតាសាលស្រុកាត់ឈោះលោក យាន ទង
ទោនចោលពាក្យបណ្តឹងរបស់លោងខ្ញុំ ដោយបោះទាំលើកាលើ ទាំយលោក
យាន ទង ពីចំមាំងប្រើពាក្យអសុរសហ្មងៗ ថាលោងខ្ញុំជាមេឆ្កោងបះបោរ ឈ
ប្រជាពលរដ្ឋឲ្យសំហាសធំជាមួយក្រុមការងារមន្ត្រីមណ្ឌលសិទ្ធិមនុស្សកម្ពុជា ទាំយ
ពីចំមាំងយោយឆំលាមឲ្យលោងខ្ញុំភ្ជាំងថា << ចាំងងាប្រយ័ត្នខ្លួនចាប់ពីថ្ងៃនេទៅ >>

ដោយសារលោងខ្ញុំ (យ៉ាប់ សោតណ្ឌ) សង្ស័យថាទាំលើសាច្រូតរបស់សង្ការីគាត
រកា មិនដោះស្រាយជួបលោងខ្ញុំ ធំរាប្រើពាក្យប្រមាថទៀតសោះ ដូចេ្នះលោងខ្ញុំសំណូម
ពរដើ្ត សិនិត ទស្តី សុំជូនដំណឹងលោកប្រធានមន្ត្រីមណ្ឌលសិទ្ធិមនុស្ស កម្ពុជាជួយសន្តិ-
ភាពធម៌ ទាក់ទងនីតិវិធីតាមផ្លូវច្បាប់ជូនលោងខ្ញុំ ។

អាស្រ័យដូចបានជម្រាបជូនលោងដើ្ត លោងខ្ញុំមានជំលឿចិត្តថាលោក
ប្រធានជួយទាក់ទងនីតិវិធីដល់លោងខ្ញុំបានតាមផ្លូវច្បាប់ ។

សូមលោកប្រធានទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីលោងខ្ញុំ !

សហគមន៍ភូមិទល្លាប់ ថ្ងៃទី ៥ ខែសេសា ឆ្នាំ 2013

យ៉ាប់ សោតណ្ឌ

សូមភ្ជាប់មកជាមួយនូវ ÷
- ឯកសារពីរសន្លឹកជាច្បាប់ចម្លង
- កាតសែតភ្ជាំពាក្យប៉ុន្តើ